# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
លេខ ០៩/០៤ .តកនសត

# ប្រធានតុលាការកំពូល

## ជម្រាបមក

### លោកប្រធានតុលាការគ្រប់ខេត្ត-ក្រុង

**កម្មវត្ថុ:** អំពីការសម្រេចជា វិធានការណ៍ប្រញាប់ និងបណ្តោះអាសន្ន

កន្លងមកតុលាការកំពូល បានកត់សម្គល់ឃើញថា ចៅក្រមយើងបានអនុវត្តត្រឹមត្រូវ តាមគោលការណ៍ច្បាប់ក្នុងការសម្រេច ជាដីកាសម្រេចតាមពាក្យសុំ និងការសម្រេចជាដីកាសម្រេចកិច្ចការប្រញាប់ ។ ដីកាសម្រេទាំងនេះគឺរក្សាបាននូវសុវត្ថិភាព សន្តិសុខ ប្រយោជន៍របស់គូភាគី ក្នុងពេលរង់ចាំរឿងអង្គសេចក្តីចូលជាស្ថាពរ ។ ប៉ុន្តែជាមួយគ្នានេះតុលាការកំពូល ក៏បានកត់សម្គាល់ឃើញនូវការខ្វះខាតខ្លះ នូវការសម្រេចទាំងពីរខាងលើនេះ ។ ដូច្នេះហើយតុលាការកំពូល សូមទាញអារម្មណ៍លោកលោកស្រី ជាចៅក្រមទាំងអស់ឱ្យគោរពបានត្រឹមត្រូវតាមគោលការណ៍ និងគោលបំណងក្នុងការចេញដីកាសម្រេចទាំងពីរនេះ ដូចខាងក្រោម ៖

**១-អំពីដីកាសម្រេចតាមពាក្យសុំ**

តាមស្មារតីសារាចរលេខ ០៥ រប.៩៧ ចុះថ្ងៃទី១១-៤-៩៧ របស់ក្រសួងយុត្តិធម៌ ដីកាសម្រេចនេះ គឺត្រូវចេញឱ្យភាគីម្ខាង ដែលសុំក្នុងករណីដែលមានការប្រញាប់ត្រូវការជាបន្ទាន់ដើម្បីជៀសវៀងមហន្តរាយដល់ផលប្រយោជន៍របស់ខ្លួន ដីកានេះមិនត្រូវធ្វើឱ្យប៉ះពាល់ ឬ ខូចខាតផលប្រយោជន៍របស់ជនដទៃក្រៅពីគូភាគី និងប៉ះពាល់ដល់អង្គសេចក្តីដែរ។ភាគីដែលមិនសុខចិត្តនឹងដីកានេះអាចប្តឹងសុំឱ្យពិនិត្យនិងជំនុំជម្រះលើដីកានេះបាន ។ ចៅក្រមត្រូវសម្រេចជាកិច្ចការប្រញាប់ ។

តាមស្មារតីនេះ ដីកាសម្រេចតាមពាក្យសុំត្រូវគោរពតាមគោលការណ៍

-ត្រូវជូនដំណឹងឱ្យភាគីម្ខាងទៀតបានដឹង និងប្តឹងតវ៉ា ។

-មិនត្រូវចេញឱ្យអនុវត្តចំពោះ អចលនទ្រព្យ ឬ រឿងក្តី ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរ និងស្មុគស្មាញទេ ។ចំពោះរឿងទាំងនេះត្រូវជំនុំជម្រះជាកិច្ចការប្រញាប់តែម្តង ។

-ខ្លឹមសារនៃការសម្រេចមិនត្រូវឱ្យប៉ះពាល់ដល់រឿងអង្គសេចក្តីទេ គឺការសម្រេចនេះគ្រាន់តែជាវិធានការណ៍ការពារមហន្តរាយជាបណ្តោះអាសន្នប៉ុណ្ណោះ ។

-នៅពេលដែលភាគីម្ខាងទៀត ឬ តតីយជនចូលមកប្តឹងតវ៉ា ហើយតុលាការមិនត្រូវយកដីកានេះទៅអនុវត្តទៀតទេ ត្រូវរង់ចាំការជំនុំជម្រះជាកិច្ចការប្រញាប់សិន ។

**២-អំពីដីកាសម្រេចកិច្ចការប្រញាប់**

ក្រោយពេលដែលបានទទួលពាក្យបណ្តឹងសុំកិច្ចការប្រញាប់ ឬ ពាក្យបណ្តឹងទាស់ពីដីកាសម្រេចតាមពាក្យសុំហើយចៅក្រមត្រូវតែរៀបចំដាក់រឿងនេះជំនុំជម្រះជាកិច្ចការប្រញាប់ ។ នីតិវិធីនៃការចាត់ការរឿងកិច្ចការប្រញាប់នេះត្រូវផ្អែកតាមសារាចរលេខ០៤ សរច ៨៤ ចុះថ្ងៃទី០៨-០៩-៨៤ របស់ក្រសួងយុត្តិធម៌ និងតាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ដែលបានបើកសិទ្ធិឱ្យលោកប្រធានតុលាការខេត្ត-ក្រុង ចេញជាដីកាសម្រេចកិច្ចការប្រញាប់ក្នុងការសម្រេចឱ្យផ្អាក ឬ មិនឱ្យផ្អាកការអនុវត្តសាលក្រម ។

តុលាការកំពូល សូមធ្វើការណែនាំបន្ថែម លើការជំនុំជម្រះកិច្ចការប្រញាប់ដូចខាងក្រោម ៖

-ត្រូវជំនុំជម្រះដោយចេញដីកាកោះ ហៅគូក្តី ឬ មេធាវី បើសិនជាមានតែពុំចាំបាច់មានតំណាងអយ្យការចូលរួមទេ ។ បើអវត្តមានភាគីណាមួយត្រូវជូនដំណឹងឱ្យភាគីនោះ ។

-មុននឹងសម្រេចសេចក្តី ចៅក្រមត្រូវពិចារណាដល់ផលប៉ះពាល់ ឬ ការខូចខាតអន្តរាយនានាដល់គូភាគីដោយសារតែការអនុវត្តសេចក្តីសម្រេចនេះ ។

-គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ពីដីកាសម្រេចកិច្ចការប្រញាប់នេះ ។

-ក្នុងការសម្រេច ត្រូវឈរលើគោលការណ៍ ដូចតទៅនេះ ៖

ក-រក្សាស្ថានភាពដដែល ដូចពេលមិនទាន់ប្តឹងផ្តល់គ្នា

ខ-គ្រាន់តែជាវិធានការណ៍បណ្តោះអាសន្ន រង់ចាំការសម្រេចដល់អង្គសេចក្តីជាស្ថាពរ

គ-មិនប៉ះពាល់ដល់អង្គសេចក្តី

ឃ-មិនធ្វើឱ្យខូចប្រយោជន៍ ដល់ភាគីណាមួយមុនអង្គសេចក្តីចូលជាស្ថាពរ ។

ង-មិនត្រូវដកហូតទ្រព្យសម្បត្តិពីភាគីម្ខាង ដែលកំពុងកាន់កាប់ទៅឱ្យភាគីម្ខាងទៀតកាន់កាប់ទេ

នៅពេលអនុវត្តដីកាសម្រេចកិច្ចការប្រញាប់ ត្រូវធ្វើកំណត់ហេតុឱ្យបានច្បាស់លាស់ដោយបញ្ជាក់នូវកាលបរិច្ឆេទអនុវត្ត សមាសភាពដែលចូលរួម ទំហំ ប្រភេទ និងចំនួនទ្រព្យសម្បត្តិដែលហាមឃាត់ និងវិធានការណ៍គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិទាំងនោះ រួចឱ្យអ្នកចូលរួម អ្នកថែរក្សា ព្រមទាំងគូភាគីចុះហត្ថលេខា និងផ្តិតមេដៃលើកំណត់ហេតុជាភស្តុតាង ។

-បណ្តឹងឧទ្ធរណ៍ ពីដីកាសម្រេចកិច្ចការប្រញាប់ ពុំមានអានុភាពផ្អាកការអនុវត្តទេ ប៉ុន្តែមុននឹងសម្រេចសេចក្តីចៅក្រមត្រូវពិចារណាឲ្យបានជិតដល់នូវផលប៉ះពាល់ ឬ ការខូចខាតអន្តរាយនានាដល់គូភាគីដោយសារតែការអនុវត្តសេចក្តីសម្រេចនេះ ដែលជាការទទួលខុសត្រូវផ្ទាល់របស់ចៅក្រម ។រយៈពេលប្តឹងសាទុក្ខ និងបណ្តឹងសាទុក្ខពីសាលដីកាកិច្ចការប្រញាប់របស់សាលាឧទ្ធរណ៍ ទើបត្រូវផ្អាកការអនុវត្តសិនរហូតដល់តុលាការកំពូលជំនុំជម្រះជាស្ថាពរតាមត្រា១៣ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនិងតាមមាត្រា២១៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអនុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

ខ្ញុំសង្ឃឹមថា ការកត់សម្គាល់និងការណែនាំរបស់តុលាការកំពូលខាងលើនេះ នឹងបានជាជំនួយស្មារតីដល់ចៅក្រមទាំងអស់ ដើម្បីត្រិះរិះពិចារណា និងសម្រេចសេចក្តីឲ្យបានត្រឹមត្រូវជៀសវាងឥទ្ធិពលអាក្រក់ដល់សណ្តាប់ធ្នាប់និងប្រយោជន៍របស់ពលរដ្ឋ ។

សូមលោកទទួលនូវការរាប់អានពីខ្ញុំ

ធ្វើនៅភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៤

**ឌិត មុន្ទី**

<u>ចម្លងជូន</u>

-ក្រសួងយុត្តិធម៌

-សាលាឧទ្ធរណ៍

-ឯកសារ